ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation- Religion- King*


រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia
គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
Cambodian Special Economic Zone Board


លេខ ៥៦៥/២២ គ.ស.ព

ថ្ងៃ ពុធ ១៤ កើត ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ. ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២២

## ជម្រាបជូន

## លោកប្រធានក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

**កម្មវត្ថុ:** ករណីសំណើសុំប្តូរឈ្មោះតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី។

**យោង:**
- ពាក្យស្នើសុំរបស់ក្រុមហ៊ុន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ដែល
- អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- អនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ភ្នំពេញ
- អនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី
- សេចក្តីប្រកាសព័ត៌មានរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១
- កំណត់ហេតុកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធាន ជ្រាបថា: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា “គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា” បានឯកភាពទទួលស្គាល់នូវសំណើសុំប្តូរឈ្មោះតំបន់សេដ្ឋកិច្ចពិសេស ភ្នំពេញ និងតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី ដែលមានខ្លឹមសារដូចខាងក្រោម÷

- តំបន់សេដ្ឋកិច្ចពិសេស ភ្នំពេញ ត្រូវបានប្តូរឈ្មោះទៅជា **តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ។**

-តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី ត្រូវបានប្តូរឈ្មោះទៅជា **តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ប៉ោយប៉ែត**។

លោកប្រធាន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ លើរាល់ករណីការលើកទឹកចិត្តដែលក្រុមហ៊ុនធ្លាប់បានទទួលពីរដ្ឋកន្លងមក និងក្នុងករណីមានបាតុភាពជាយថាហេតុ ដែលកើតចេញពីការស្នើសុំប្តូរឈ្មោះតំបន់សេដ្ឋកិច្ចពិសេសទាំងពីរខាងលើនេះ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា សូមរក្សាសិទ្ធិក្នុងការកែប្រែនូវគោលការណ៍ឯកភាពស្នើសុំប្តូរឈ្មោះតំបន់សេដ្ឋកិច្ចពិសេសនេះ ក្នុងករណីមានការតវ៉ាណាមួយជាយថាហេតុលើសំណើសុំខាងលើនេះ។

សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ ពីខ្ញុំ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គលេខាធិការ**

**សុខ ចិន្តាសោភា**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធាន ក.អ.ក
- **ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធាន ក.អ.ក
- សាលារាជធានីភ្នំពេញ
- សាលាខេត្តបន្ទាយមានជ័យ
- ឯកសារ-កាលប្បវត្តិ